

អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ ២០២០

## ពង្រឹងសហគមន៍ជាតិរឹងមាំ





## ពង្រឹងស្មារតីដល់ក្រុមគោលដៅ

## ធ្វើការជាមួយអ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច





## តភ្ជាប់អាជ្ញាធរ និង សង្គមស៊ីវិល

## ការងារអភិវឌ្ឍន៍ប្រកប ដោយភាពឆ្នៃប្រឌិត និងចីរភាព





# សេចក្ដីផ្ដើម

ឆ្នាំ២០២០ បានជម្រុញឱ្យយើងគិតពិចារណាឡើងវិញនូវរាល់អ្វីៗគ្រប់យ៉ាង! យើងបានរៀនជំនាញថ្មីៗ និងវាក្យសព្ទថ្មីៗតួយ៉ាងដូចជា កូវីដ-១៩ ការបិទខ្ទប់ ការរក្សាគម្លាតសុវត្ថិភាពសង្គម ការកាត់បន្ថយការរីករាលដាល កម្មវិធីប្រជុំ តាមប្រព័ន្ធអ៊ីនធឺណិត (Zoom)។ល។ វាជាពេលវេលាប្រឈម ប៉ុន្តែយើងជឿជាក់ថារាល់ឧបសគ្គ ឬការលំបាកគឺជាឱកាសដើម្បីរៀន និងរីកចម្រើន។

វាជាឱកាសល្អសម្រាប់បុគ្គលិកអាយស៊ីស៊ី ក្នុងការសិក្សានិងការត្រួតពិនិត្យឡើងវិញ នូវគោលនយោបាយអាយស៊ីស៊ីផ្សេងៗឱ្យកាន់តែស៊ីជម្រៅតាមរយៈការឆ្លុះបញ្ចាំង ក្នុងកំឡុងពេលនៃការងារចុះសហគមន៍ ត្រូវបានផ្អាក។

ការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំ និងអំពើពុករលួយ នៅតែជាចំណុចផ្ដោតចម្បងក្នុងឆ្នាំ២០២០ ក្នុងអង្គការរបស់យើង។ អង្គការអាយស៊ីស៊ី ប្ដេជ្ញាចិត្តធ្វើឱ្យប្រាកដថា អង្គការអនុវត្តតាមច្បាប់ថ្មីរបស់កម្ពុជា ស្ដីពីការប្រឆាំងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។ ការបកប្រែជាភាសាខ្មែរនៃគោលនយោបាយស្ដីពីការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំ និងអំពើពុករលួយ ត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីធានាថាក្រុមរបស់យើងទាំងអស់ យល់ច្បាស់អំពីគោលការណ៍គ្មានការអត់អោន/លើកលែងនេះ។

ផ្អែកលើការឆ្លុះបញ្ចាំង និងការពិភាក្សាជាមួយក្រុមការងារ និងការសិក្សារៀនសូត្របន្ថែមពីដៃគូផ្ដល់មូលនិធិ គោលនយោបាយ ស្ដីពីការការពារមនុស្សពេញវ័យងាយរងគ្រោះត្រូវបានកែសម្រួល ហើយប្ដូរឈ្មោះទៅជាគោលនយោបាយ ស្ដីពីការការពារការធ្វើអាជីវកម្មនិងការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ។ វាជាគោលនយោបាយគ្មានការលើកលែងទីបី របស់អង្គការអាយស៊ីស៊ី។ គោលនយោបាយនេះដាក់ចេញនូវវិធីសាស្ត្ររបស់អង្គការអាយស៊ីស៊ី ដើម្បីការពារ និងដោះស្រាយនឹងការធ្វើអាជីវកម្ម និងការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ និងដើម្បីធានាឱ្យមានការឆ្លើយតបសមស្រប និងប្រយ័ត្នប្រយែង ប្រសិនបើការធ្វើអាជីវកម្មនិងការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទកើតឡើង។ គោលនយោបាយនេះ ពិពណ៌នាពីការរំពឹងទុកច្បាស់លាស់នៃការប្រព្រឹត្តិ និងការអនុវត្តល្អ នៅពេលមានទំនាក់ទំនងជាមួយមនុស្សពេញវ័យងាយរងគ្រោះ ឬមនុស្សងាយបាត់បង់ឱកាស។

ចាប់ពីពេលក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងក្រុមនាយកប្រតិបត្តិរបស់អង្គការអាយស៊ីស៊ី បានឯកភាពគ្នាថាមធ្យោបាយល្អបំផុត សម្រាប់អង្គការអាយស៊ីស៊ី គឺការផ្លាស់ប្ដូរទិសដៅ ដោយបំប្លែងខ្លួនទៅជាអង្គការក្នុងស្រុកមក មានកិច្ចប្រជុំក្រុមប្រឹក្សាភិបាលច្រើនក្នុងឆ្នាំ២០២០ ពីដំណើរការនៃការធ្វើមូលដ្ឋានីយកម្ម ដោយប្រើឧបករណ៍វិភាគហៅកាត់ថាស្វត (SWOT) ដើម្បីវាយតម្លៃកត្តាខាងក្នុងនិងកត្តាខាងក្រៅ ចំពោះផែនការដែលបានកំណត់ ឆ្លុះបញ្ចាំងពីការរៃអង្គាសមូលនិធិ។ល។ អង្គការអាយស៊ីស៊ីជឿជាក់ថាអភិបាលកិច្ចល្អ គឺជាចំណុចសំខាន់បំផុតនៃដំណើរការរបស់អង្គការប្រកបដោយជោគជ័យនិងប្រសិទ្ធភាព ដូច្នេះយើងកំពុងខិតខំកសាងអភិបាលកិច្ចរឹងមាំ តាំងពីផ្ដើមចាប់ផ្ដើមដំបូង។

នៅក្នុងរបាយការណ៍នេះ យើងរៀបចំដោយស្ថិតនៅក្រោមយុទ្ធសាស្ត្រផ្ដោតរបស់អង្គការរួមមាន៖

១) ការចិញ្ចឹមជីវិតដោយខ្លួនឯង
២) សង្គមស៊ីវិលបុរេសកម្ម
៣) យុត្តិធម៌ផ្នែកច្បាប់

# ការចិញ្ចឹមជីវិតដោយខ្លួនឯង

## យុទ្ធសាស្ត្រផ្តោតអាយស៊ីស៊ី

អាជីវកម្មកសិកម្ម នៅតែរឿងថ្មីសម្រាប់ទាំងសហគមន៍កសិកម្ម និងយុវជន នៅតាមភូមិគោលដៅគម្រោងហ្វាសរបស់អង្គការអាយស៊ីស៊ី ដូច្នេះពួកគេត្រូវរៀនពីរបៀបបំពេញតួនាទីក្នុងការធ្វើពាណិជ្ជកម្ម ដែលមានលក្ខណៈទូលំទូលាយ និង ជំរុញការផ្សារភ្ជាប់ទំនាក់ទំនង ត្រូវរៀនពីរបៀបវិភាគតម្រូវការផលិតកម្ម និងខ្សែចង្វាក់ផ្គត់ផ្គង់ ការវិភាគប្រាក់ចំណេញ និងជំនាញគ្រប់គ្រងទីផ្សារផ្សេងទៀត។ អាជីវកម្មភ្ញាស់កូនមាន់ ក៏ជារឿងថ្មីសម្រាប់កសិករគំរូ នៅតាមតំបន់គោលដៅ។ ជំនាញធ្វើអាជីវកម្ម និងដោះស្រាយបញ្ហា ការថែទាំកូនមាន់ និងការគ្រប់គ្រងការផ្គត់ផ្គង់ នៅតែត្រូវការការពង្រឹងថែមទៀត។

ទោះយ៉ាងណាក៏ដោយ មានក្រុមប្រមូលផ្តុំថ្មីចំនួន១០ ដែលត្រូវបានបង្កើតឡើង និងដំណើរការបានល្អ ជាចំណែកមួយ នៃរចនាសម្ព័ន្ធអាជីវកម្ម ដើម្បីសម្រួលដល់ការភ្ជាប់ទំនាក់ទំនងបណ្តាញ រវាងក្រុមជួយខ្លួនឯង និងសហគមន៍កសិកម្ម។ក្រុមប្រមូលផ្តុំទាំង១០ (១ក្រុមក្នុងមួយភូមិ) ក៏អាចធ្វើការ ជាមួយមន្ទីរកសិកម្មខេត្ត ទាក់ទងនឹងដំណើរការផ្សព្វផ្សាយនិងលក់ផលិតផលកសិកម្ម។ កិច្ចសន្យាពាណិជ្ជកម្មថ្មី ត្រូវបានចុះហត្ថលេខា រវាង សហគមន៍កសិកម្ម និងសហគមន៍កសិកម្ម ជំរុញការចិញ្ចឹមមាន់ខ្មែរ។ ដើម្បីបំពេញតម្រូវការ សហគមន៍កសិកម្ម បានចុះកិច្ចសន្យាជាមួយក្រុមប្រមូលផ្តុំ ហើយចាប់ផ្តើមទិញមាន់ និងស៊ុតពីក្រុមនីមួយៗ។







វិធីសាស្ត្រនេះ ធ្វើឱ្យក្រុមប្រមូលផ្តុំទាំង១០បង្កើនសមត្ថភាពក្នុងការរកប្រាក់ចំណូល។ នេះ គឺជាការបង្ហាញពីការសម្រេចបានលទ្ធផលរបស់គម្រោងដោយជោគជ័យ៖ បង្កើនប្រាក់ចំណូលដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋានរបស់ពួកគាត់។ កាលពីមុនពួកគាត់អាចលក់បានតែមាន់ តែពេលនេះពួកគាត់ក៏អាចលក់ស៊ុត ទៅឱ្យសហគមន៍កសិកម្មផងដែរ។

កសិករគំរូ២៨នាក់ ក្នុង១៤ភូមិ (២នាក់ក្នុងមួយភូមិ) ត្រូវបានជ្រើសរើស។ ពួកគាត់ទាំងអស់គ្នាចិញ្ចឹមមាន់ និងដាំបន្លែ។ បួននាក់ក្នុងចំណោមពួកគាត់ ចិញ្ចឹមកង្កែបបន្ថែមដោយសារមានកន្លែងទីធ្លាធំ។ កសិករគំរូ ដែលបានជ្រើសរើសទាំងអស់ បានអនុវត្តជំនាញរបស់ពួកគាត់ យ៉ាងសកម្ម ហើយពួកគាត់មានឆន្ទៈជួយក្រុមផលិតកម្មកសិកម្មផ្សេងៗទៀត ពីព្រោះ ពួកគាត់ចង់ឃើញអ្នកភូមិក្រីក្រមានជីវភាពប្រសើរឡើង រកប្រាក់ចំណូលបន្ថែម និងផ្លាស់ប្តូរជីវភាពរស់នៅជាវិជ្ជមាន ជាមួយនឹងសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេស។ ជាទូទៅ ជីវភាពរស់នៅរបស់ពួកគាត់មានភាពប្រសើរឡើងច្រើន ហើយការធ្វើចំណាកស្រុកខុសច្បាប់ បានថយចុះគួរឱ្យកត់សម្គាល់។

# សន្តមស៊ីវិលបុរេសកម្ម

## យុទ្ធសាស្ត្រផ្តោតអាយស៊ីស៊ី

គម្រោងកាត់បន្ថយហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់របស់អង្គការអាយស៊ីស៊ី បានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមឃ្លាំមើលដែលមានស្រាប់ ក្នុងការបម្រើសហគមន៍ ជាយន្តការបណ្តាញសុវត្ថិភាពផ្អែកលើសហគមន៍ជាមូលដ្ឋាន។ ពួកគាត់ ត្រូវបានបង្កើតចេញពីក្រុមជួយខ្លួនឯង ហើយសមាជិកក្រុមឃ្លាំមើល គឺជាអ្នកស្ម័គ្រចិត្ត។ ពួកគាត់ភាគច្រើន ជាអតីតជនរងគ្រោះ ជាគ្រូបង្រៀននិងជាមនុស្សចំណាស់ជាដើម។ ទោះបីក្រុមទាំងនោះ នៅក្មេងខ្ចីក្នុងកិច្ចការងាររបស់ខ្លួន ពួកគាត់មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការការពារអ្នកភូមិពីការជួញដូរមនុស្ស។ មានក្រុមឃ្លាំមើលចំនួន៣១ នៅតែខិតខំធ្វើការ ទោះបីជាមានការរឹតបន្តឹង ដោយសារកូវីដ-១៩ ប៉ះពាល់ដល់ជីវភាពរស់នៅ និងសហគមន៍របស់ពួកគាត់ក៏ដោយ។ ទោះយ៉ាងណាក៏ដោយ ការគិតវិជ្ជមាន គុណតម្លៃ និងការជឿទុកចិត្ត លើកិច្ចការងាររបស់ក្រុមឃ្លាំមើល អាចរួមចំណែកក្នុងការជួយសហគមន៍របស់ពួកគាត់ឱ្យមានសុវត្ថិភាព ជៀសឆ្ងាយពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។ ពួកគាត់ទទួលការបំពាក់បំប៉ន ឱ្យមានការប្តេជ្ញាចិត្ត និងឆន្ទៈក្នុងការក្លាយជាផ្នែកមួយនៃក្រុមឃ្លាំមើល ដើម្បីបម្រើសហគមន៍ចេញពីបេះដូងរបស់ពួកគាត់។ សមាជិកមួយចំនួន បាននិយាយថាពួកគាត់មានមោទនភាពចំពោះខ្លួនឯង ដែល






ក្លាយជាសមាជិករបស់ក្រុមឃ្លាំមើល ក្នុងការចូលរួមចំណែក ពេលវេលាផ្ទាល់ខ្លួន ដើម្បីបម្រើសង្គម ពីព្រោះសង្គមត្រូវការឱ្យពួកគាត់ជួយ ដោយសារមានករណីអយុត្តិធម៌ជាច្រើន ដែលកើតឡើងចំពោះសហគមន៍របស់ពួកគាត់ រួមមានការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់។ល។

ករណីខ្លះបានកើតឡើង ចំពោះសាច់ញាតិរបស់ពួកគាត់ ធ្វើឱ្យឈឺចាប់រងទុក្ខយ៉ាងខ្លាំង ដែលបណ្តាលឱ្យសាច់ញាតិទាំងនោះបាត់បង់ពេលវេលា លុយកាក់ ហើយកាន់តែក្រទៅៗ។ ពួកគាត់មួយចំនួនបាននិយាយថា ក្នុងឆ្នាំនេះពួកគាត់មិនសូវសកម្មក្នុងកិច្ចការងារ និងការទទួលខុសត្រូវរបស់ពួកគាត់ទេ ដោយសារតែការព្រួយបារម្ភពីកូវីដ-១៩ ហើយពួកគាត់ត្រូវធ្វើតាមការណែនាំ ពីរាជរដ្ឋាភិបាល និងស្តាប់បញ្ជាអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ-១៩។ ប្រសិនបើស្ថានការណ៍ក្លាយជាធម្មតាវិញ ពួកគាត់សង្ឃឹមថាពួកគាត់នឹងបំពេញកិច្ចការងារនិងការទទួលខុសត្រូវកាន់តែសកម្ម ហើយពួកគាត់ទន្ទឹងរង់ចាំឱកាស នៅឆ្នាំក្រោយ ដើម្បីផ្សព្វផ្សាយ នូវអ្វីដែលពួកគាត់បានដឹង ទៅដល់សហគមន៍ដទៃទៀត។

ក្រុមឃ្លាំមើល ក៏បានខិតខំប្រឹងប្រែងចូលរួមក្នុងការពិភាក្សាឆ្លុះបញ្ចាំង ជាមួយអ្នកផ្តល់សិទ្ធិខាងសីលធម៌ផ្សេងទៀត (មេដឹកនាំសាសនា ព្រឹទ្ធាចារ្យ និងក្រុមជួយខ្លួនឯង) និងអ្នកផ្តល់សិទ្ធិក្នុងក្របខ័ណ្ឌច្បាប់ (មេភូមិ ក្រុមប្រឹក្សាឃុំសង្កាត់ រដ្ឋបាលប៉ូលីស និងគ្រូបង្រៀន) អំពីរបៀបលើកទឹកចិត្តឱ្យមានការចូលរួម និងសហការពីវិស័យឯកជន ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងកេងប្រវ័ញ្ច និងធ្វើឱ្យវិស័យ ទទួលខុសត្រូវចំពោះច្បាប់។

# យុត្តិធម៌ផ្នែកច្បាប់

## យុទ្ធសាស្ត្រផ្តោតអាយស៊ីស៊ី

ចាប់ពីឆ្នាំ២០១៦ ក្រុមការងារគម្រោងអាយប៊ីស៊ីឌីអ៊ីរបស់អង្គការអាយស៊ីស៊ី រួមជាមួយអ្នកភាសាវិទូមកពី អង្គការអេសអាយអិល(SIL) បានធ្វើការលើការអភិវឌ្ឍប្រព័ន្ធសរសេរជាភាសាចារាយ។ ការអភិវឌ្ឍនេះត្រូវបានធ្វើឡើង ដោយការចូលរួមយ៉ាងជិតស្និទ្ធ ជាមួយជនជាតិដើមចារាយនិងដោយការសហការជាមួយអាជ្ញាធរ មូលដ្ឋានក្នុងខេត្តរតនគិរីក្រសួងអប់រំ យុវជន និងកីឡា(អយក) និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតដែលមានចំណាប់អារម្មណ៍លើជនជាតិដើមចារាយ។ អក្ខរាវិរុទ្ធដែលយកភាសាខ្មែរ ជាមូលដ្ឋានសម្រាប់ចារាយ ត្រូវបានធ្វើពិសោធន៍សាកល្បងរយៈពេល២ឆ្នាំ ហើយចំណុចសំខាន់នៅឆ្នាំ២០២០ គឺអក្ខរាវិរុទ្ធនោះត្រូវបានអនុម័ត ដោយក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០។ ចាប់ពីពេលនោះមកអង្គការអាយស៊ីស៊ី បានបង្រៀនឱ្យចេះអាន បានផលិតសៀវភៅនិងខិតប័ណ្ណផ្សព្វផ្សាយ។ ដូចគ្នាផងដែរ ចម្រៀងនិងសៀវភៅ ត្រូវបានចែករំលែកតាមរយៈបណ្តាញសង្គមហ្វេសប៊ុក ពីស្ថាប័នដៃគូរបស់យើង។

ខណៈពេលដែលអង្គការអាយស៊ីស៊ី កំពុងធ្វើការលើផែនការនិងការស្វែងរកការគាំទ្រមតិ សម្រាប់អក្ខរក្រមចារាយឱ្យមានការបង្រៀន នៅតាមសាលារដ្ឋ ដែលនឹងជួយសហគមន៍ចារាយទទួលយកអក្ខរាវិរុទ្ធនេះ ជាអក្ខរក្រមផ្លូវការសម្រាប់ជនជាតិដើមចារាយ នៅប្រទេសកម្ពុជា អង្គការអាយស៊ីស៊ី បានចាប់ផ្តើមឱ្យមានការចូលរួមពីយុវជនចារាយក្នុងការលើកកម្ពស់ការអប់រំផ្អែកលើភាសាកំណើតរបស់ខ្លួន។ យុវជនចារាយខ្លះ បានចូលរួមវគ្គខ្លី ស្តីអំពីរបៀបប្រើអក្ខរក្រមចារាយ ជាមួយបុគ្គលិកគម្រោងរបស់អង្គការអាយស៊ីស៊ី។ ពួកគេនឹងក្លាយជាជនបង្គោលដែលអាចលើកកម្ពស់ពីសារៈសំខាន់នៃការអប់រំពហុភាសាផ្អែកលើភាសាកំណើត ជាមូលដ្ឋានការបង្កើនការយល់ដឹង តាមរយៈបណ្តាញទាំងនេះ នឹងបង្កើតជាសម្ពាធពីក្រោមទៅលើ និងបង្ហាញពីតម្រូវការកើនឡើងសម្រាប់ការប្រើប្រាស់។





អង្គការអាយស៊ីស៊ី បានជ្រើសរើសវិធីសាស្ត្រពង្រឹងស្មារតីសហគមន៍ ដើម្បីជួយសហគមន៍ឱ្យជួយខ្លួនឯង។ ការគាំទ្រកសិកម្មក្នុងគម្រោង ទាមទារឱ្យមានការវិនិយោគពីអ្នកទទួលផល និងលើកទឹកចិត្តដល់ការប្រើប្រាស់ធនធានដែលមានស្រាប់នៅក្នុងមូលដ្ឋាន ដោយមិនពឹងផ្អែកលើអ្នកខាងក្រៅ។ នេះបានកសាងភាពគ្រប់គ្រាន់ដោយខ្លួនឯងក្នុងចំណោមអ្នកទទួលផល។ គម្រោងហ្វាសរបស់អង្គការអាយស៊ីស៊ី បានជម្រុញឱ្យសហគមន៍ដឹកនាំធ្វើសកម្មភាពដោយខ្លួនឯង។ ការកសាងភាពជាម្ចាស់នៅមូលដ្ឋានដើម្បីធានាបាននូវការអនុវត្តរយៈពេលវែង។ ការអនុវត្តវិធីសាស្ត្រផ្អែកលើសិទ្ធិជាមូលដ្ឋាន(RBA) គម្រោងបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអ្នកផ្តល់សិទ្ធិសំខាន់ៗដែលមានកាតព្វកិច្ចគាំទ្រដល់អ្នកទទួលផល (អ្នកមានសិទ្ធិ)។ សំខាន់នោះគឺ គម្រោងធ្វើឱ្យតួនាទីរបស់អ្នកផ្តល់សិទ្ធិ សកម្មឡើងវិញ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរសម្រាប់អ្នកមានសិទ្ធិ។ ឧទាហរណ៍ ឪពុកម្តាយ លោកគ្រូអ្នកគ្រូ សាលារៀន អាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានភារកិច្ចសំខាន់ៗក្នុងការការពារ និងបំពេញសេចក្តីត្រូវការក្មេងៗរបស់ពួកគាត់ ក្នុងនាមជាអ្នកផ្តល់សិទ្ធិ។

សមត្ថភាព និងជំនាញដែលទទួលបានពីគម្រោង មានការតាមដានយ៉ាងយកចិត្តទុក ការបង្វឹកនិងការគាំទ្រ។ ធ្វើយ៉ាងនេះគឺដើម្បីធានាថា អ្នកទទួលផលពិតជារៀនសូត្របាន និងប្រើប្រាស់បានក្នុងរយៈពេលវែង ការអនុវត្តនឹងមិនធ្វើឱ្យចំណេះដឹងនិងជំនាញរលាយបាត់ងាយៗទេ តែធ្វើឱ្យប្រសើរឡើងសម្រាប់អ្នកទទួលផលគ្រប់គ្នា ដែលជាមនុស្សវ័យចំណាស់ ជាយុវជន និងជាកុមារ។

# អង្គការអាយស៊ីស៊ី
## ជាស្ថាប័នរៀនសូត្រ

អង្គការអាយស៊ីស៊ី នៅតែបន្តជាអង្គការរៀនសូត្រ ដោយការឆ្លុះបញ្ចាំង ការធ្វើវិភាគ និងការស្តាប់ ដើម្បីអភិវឌ្ឍ និងពង្រឹងអង្គការ។ ដូច្នេះ ទោះបីជាស្ថិតក្នុងឆ្នាំដ៏លំបាក នៅឆ្នាំនេះដោយសារតែកូវីដ-១៩ និងសម្ពាធតានតឹងផ្សេងៗ ដែលបានជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃ ពីរបៀបដែលយើងធ្វើការ ពីរបៀបដែលយើងធ្វើអន្តរកម្មជាមួយមិត្តរួមការងារ និងជាមួយក្រុមគោលដៅក៏ដោយ យើងនៅតែមានអំណរ ដែលយើងមានសមត្ថភាពក្នុងការកសាងភាពធន់ នៅកន្លែងធ្វើការ សមត្ថភាពក្នុងការទប់ទល់នឹងសម្ពាធ និងកសាងភាពធន់សម្រាប់ក្រុមគ្រួសាររបស់យើង អនុវត្តតាមការយល់ដឹងការគិតសង្កេតមើល ត្រិះរិះពិចារណាកែវិធីសាស្រ្តថ្មី ដើម្បីផ្លាស់ប្តូររបៀប ដែលយើងគិតអំពីស្ថានភាពអវិជ្ជមាន និងព្រឹត្តិការណ៍អាក្រក់ និងការបង្កើនការរៀនសូត្រពីកំហុស និងការបរាជ័យ។





ជាឧទាហរណ៍ អង្គការអាយស៊ីស៊ី បានធ្វើការបណ្តុះបណ្តាលផ្ទៃក្នុងចំនួនពីរវគ្គ ស្តីពីភាពធន់សម្រាប់គ្រួសារដែលមានវិបត្តិ និងភាពធន់លើការថែទាំខ្លួនឯង។ការពិភាក្សាឆ្លុះបញ្ចាំងក្នុងកំឡុងពេលបណ្តុះបណ្តាល គឺអំពីវិធីដាំបណ្តុះនិងបន្តឱ្យមានគំនិតវិជ្ជមាន ដូច្នេះយើងអាចចាប់ផ្តើមផ្លាស់ប្តូររបៀបគិតរបស់យើង។ សមាជិកក្រុមអាយស៊ីស៊ី មានអារម្មណ៍ជឿជាក់ និងមានសមត្ថភាពក្នុងការគាំទ្រក្រុមគោលដៅរបស់ពួកគាត់ ក្នុងការពង្រឹងគ្រួសារ ដែលមានវិបត្តិ។ សមាជិកក្រុមអាយស៊ីស៊ី ទទួលបានការយល់បន្ថែម អំពីវិបត្តិនៅក្នុងគ្រួសារ និងពួកគាត់យល់ដឹង ពីសញ្ញានៃវិបត្តិនៅក្នុងគ្រួសារ ហើយបានជំរុញនាំឱ្យពួកគាត់ផ្តើមឆ្លុះបញ្ចាំង និងពិភាក្សាពីរបៀបដើម្បីកំណត់សញ្ញាដែលអាចកើតឡើង នៅក្នុងគ្រួសាររបស់ពួកគាត់ផ្ទាល់។ បុគ្គលិកអាយស៊ីស៊ី មានឆន្ទៈចែករំលែកបញ្ហាជាក់ស្តែងផ្ទាល់ខ្លួន ក្នុងអំឡុងពេលបណ្តុះបណ្តាល។ កាលណាពួកគាត់កាន់តែឆ្លុះបញ្ចាំង ពួកគាត់កាន់តែអាចស្វែងរកឃើញពីប្រភពនៃបញ្ហា បើទុកវាចោលដោយគ្មានការយកចិត្តទុកដាក់ដោះស្រាយ អាចបង្កបញ្ហាកាន់តែធ្ងន់ធ្ងរ។ ដូច្នេះ បុគ្គលិកអាយស៊ីស៊ី បានបង្ហាញចំណាប់អារម្មណ៍ថា ពួកគាត់ត្រូវតែមានការប្រុងប្រយ័ត្ន និងរកវិធីដើម្បីរក្សាទំនាក់ទំនងនៅក្នុងគ្រួសារ។ លើសពីនេះទៅទៀត នៅពេលពួកគាត់យល់អំពីវិបត្តិ ជាពិសេសសញ្ញាដែលពួកគាត់អាចកត់សម្គាល់ និងកំណត់អត្តសញ្ញាណ នៅក្នុងគ្រួសារក្រុមគោលដៅ ពួកគាត់អាចផ្តល់ការគាំទ្រដល់គ្រួសារទាំងនោះបាន។



# ផែនការសម្រាប់២០២១

ឆ្នាំ២០២១ នឹងចាប់ផ្តើមការស្រាវជ្រាវអំពីរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពទាក់ទងនឹងការប្រឆាំងការជួញដូរមនុស្សនៅស្រុកព្រះស្តេច ដើម្បីធានាថារាល់បញ្ហា និងបញ្ហាប្រឈមមាននៅក្នុងការវិភាគបញ្ហា ដូចដែលយើងកំពុងគ្រោង នឹងបន្ថែមសមាសធាតុនៃរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ចូលទៅក្នុងគម្រោង ការប្រឆាំងការជួញដូរមនុស្ស។ ជាងនេះទៅទៀត ការស្ទង់មតិ និងការសម្ភាសក្នុងដំណើរការស្រាវជ្រាវ បើកឱកាសឱ្យមានការរៀបចំគម្រោង ដែលមានការចូលរួម ទាំងឧបករណ៍ប្រមូលទិន្នន័យ ដំណាលគ្នាទាំងតួនាទីបណ្តាញអ្នកពាក់ព័ន្ធ/អ្នកមានសិទ្ធិ ដែលមានស្ត្រី កុមារ និងអ្នកទទួលផលផ្សេងៗ ហើយនិងក្រុមងាយរងគ្រោះ អាចបញ្ចេញទស្សនៈ បទពិសោធន៍ និងយោបល់របស់ពួកគេ។

ក្រៅពីការធ្វើការដំណាក់កាលបន្ទាប់នៃគម្រោងបច្ចុប្បន្ន យើងក៏បន្តការងាររៀបចំគម្រោងថ្មីចំនួន២ ជាមួយនឹងការចង់បានការផ្លាស់ប្តូរនៃការទទួលបានព័ត៌មានកាន់តែកើនឡើង និងគុណភាពកាន់តែប្រសើរឡើងនៃការអប់រំពហុភាសាផ្អែកលើភាសាកំណើតជាមូលដ្ឋាន មាននៅតាមសាលារៀនសាធារណៈក្នុងខេត្តរតនគិរី និងការកសាងភាពធន់ ទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់សន្តិសុខស្បៀងរបស់សហគមន៍ជនជាតិដើមភាគតិច។ គម្រោងថ្មីទាំងពីរនេះ មានបំណងចាប់ផ្តើមអនុវត្ត នៅក្នុងខែមករាឆ្នាំ ២០២២។

ក្រុមនាយកប្រតិបត្តិអាយស៊ីស៊ី នឹងចុះឈ្មោះរៀនតាមប្រព័ន្ធអនឡាញស្តីពីការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំក្នុងអង្គការមិនមែនរដ្ឋាភិបាល ព្រោះយើងចង់កសាងបន្ថែម នូវជំនាញ និងទំនុកចិត្តដើម្បីទប់ស្កាត់ ស៊ើបអង្កេត និងឆ្លើយតបចំពោះការក្លែងបន្លំ។ ជាមួយនឹងជំនាញទាំងនោះ យើងអាចធ្វើឱ្យប្រាកដថាធនធានរបស់អង្គការអាយស៊ីស៊ី បានទៅដល់កន្លែងដែលត្រូវការបំផុត។ យើងក៏មានគម្រោងបកប្រែម៉ូឌុលទាំងអស់នោះជាភាសាខ្មែរ ហើយប្រើសម្រាប់ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិករបស់យើង។ នេះនឹងមិនត្រឹមតែពន្យល់បង្ហាញពីមូលហេតុដែលបុគ្គល(មនុស្ស)ប្រព្រឹត្តការក្លែងបន្លំ កំណត់គោលការណ៍សំខាន់ៗនៃការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំគន្លឹះនិងដំណើរការប៉ុណ្ណោះទេ ថែមទាំងពន្យល់បង្ហាញពីអត្ថប្រយោជន៍នៃការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំ និងការបើកចំហចំពោះម្ចាស់ជំនួយ និងបុគ្គលិក ប្រសិនបើមានការក្លែងបន្លំកើតឡើង។

ក្នុងនាមជាអង្គការ អាយស៊ីស៊ីនឹងធ្វើការរៀបចំឡើងវិញជាយុទ្ធសាស្ត្រនៅឆ្នាំ២០២១។ នេះនឹងជួយឱ្យអង្គការ នៅតែបន្តបម្រើក្រុមគោលដៅរបស់ខ្លួន តាមរយៈយុទ្ធសាស្ត្រដែលបានធ្វើបច្ចុប្បន្នភាព និងសម្របខ្លួនត្រូវគ្នានឹងតម្រូវការរបស់សហគមន៍ និងចំណុចខ្លាំងរបស់អង្គការ។ យុទ្ធសាស្ត្រនេះ នឹងប្រើនៅក្នុងអង្គការចាប់ពីឆ្នាំប្រតិទិន ២០២២ ដល់ ២០២៦ ។


## ការដឹងគុណ

សូមថ្លែងអំណរគុណចំពោះបណ្តាក្រសួង និងអង្គការនានា ដែលបានផ្តល់ការគាំទ្រ និងជំនួយសប្បុរសដ៏មានសារៈសំខាន់បំផុតដល់កិច្ចការងាររបស់អង្គការអាយស៊ីស៊ី ក្នុងប្រទេសកម្ពុជា។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ Interact; Normisjon; Felm; Transform Aid International; Tearfund UK; WBTNZ; LEAD A-P; ប្រិយសម្ពន្ធគ្រីស្ទបរិស័ទកម្ពុជា ; SIL International; អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា; អង្គការ បណ្តាញមីកា; អង្គការ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល និង អង្គការ សម្ព័ន្ធចាប់ដៃ។

ដៃគូផ្តល់មូលនិធិ



**ការិយាល័យកណ្តាល អង្គការអាយស៊ីស៊ី**

ផ្ទះលេខ២១, ផ្លូវA, បុរីភ្នំពេញថ្មី - រីជេនប៍ផាក(BR)

បណ្តោយផ្លូវទ្រុងមាន់, ភូមិដំណាក់ធំ៣, សង្កាត់ស្ទឹងមានជ័យទី៣, រាជធានីភ្នំពេញ, កម្ពុជា

ប្រអប់សំបុត្រលេខ៦១២ | ទូរស័ព្ទលេខ +៨៥៥(0)៩២ ៤៦៩ ៩៣៤

អ៊ីម៉ែល info@icc.org.kh | គេហទំព័រ www.icc.org.kh